## សំរេច

**ប្រការ ១** : ប្រគល់ដី និងអាគារវិទ្យាល័យភាសាបារាំង នៅភ្នំពេញ (បច្ចុប្បន្ន សាលាមធ្យមសិក្សាពាណិជ្ជកម្ម នៃក្រសួងអប់រំ យុវជន និងកីឡា) អោយទៅរដ្ឋាភិបាលបារាំងគ្រប់គ្រង ដែលជាថ្នូរទៅនិងការផ្តល់វិភាគទានសំរាប់ការសាងសង់ឡើងវិញ នូវអាគារសាលាមធ្យមសិក្សាពាណិជ្ជកម្ម ។

**ប្រការ ២** : ប្រគល់ទីតាំងអាគារនិងដីមជ្ឈមណ្ឌលកូឡាបទី៣ ស្ថិតនៅភូមិទ្រា សង្កាត់ស្ទឹងមានជ័យ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ ដែលមានផ្ទៃក្រឡាចំនួន ៦៤៥២.២៦ ម៉ែត្រក្រឡា អោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា សំរាប់ការងារសាងសង់សាលាមធ្យមសិក្សា ពាណិជ្ជកម្ម ។

**ប្រការ ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង អប់រំយុវជន និងកីឡា រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តតាមសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

≈≈≈

## សេចក្តីសំរេច លេខ ០៥ សសរ
## ស្តីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីស្រាវជ្រាវ និងទប់ស្កាត់ការនាំចូលតាមច្រកព្រំដែននូវសត្វរស់ ផលិតផលមានដើមកំណើតពីសត្វ និងគ្រឿងបរិភោគដែលនាំអោយប៉ះពាល់ដល់សុខភាពសាធារណៈ

-. បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

www.pheakdeylaw.com

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមសភាពការណ៍ការចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

**ប្រការ ១** : បង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីស្រាវជ្រាវ និងទប់ស្កាត់នូវការនាំចូលតាមច្រកព្រំដែននានា នូវសត្វរស់ ផលិតផលមានដើមកំណើតពីសត្វ និងគ្រឿងបរិភោគ ដែលនាំអោយប៉ះពាល់ដល់សុខភាពសាធារណៈ ដែលមានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១-ឯកឧត្តម **ហុង ស៊ុនហួត** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល | ជាប្រធាន |
| ២-ឯកឧត្តម **ចំរុង តុងអ៊ីច** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | អនុប្រធាន |
| ៣-ឯកឧត្តម **សុក ស៊ីផាន់ណា** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៤-ឯកឧត្តម **ម៉ែន ស៊ីម៉ន** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកទីចាត់ការគយ និង រដ្ឋាករ | សមាជិក |
| ៥-ឯ.ឧ ឧត្តមសេនីយទោ **នេត សាវឿន** | ប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ | សមាជិក |
| ៦-ឯ.ឧ ឧត្តមសេនីយត្រី **តេខ ឈួន** | មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ៧-ឯកឧត្តម | អភិបាលខេត្ត ដែលមានការពាក់ព័ន្ធ | សមាជិក |

**ប្រការ ២** : គណៈកម្មការអន្តរក្រសួងនេះ មានភារកិច្ចដូចតទៅ :

- ស្រាវជ្រាវ និងត្រួតពិនិត្យ អោយបានហ៊្សឹងម៉ាត់ការនាំចូលតាមបណ្តាច្រកព្រំដែននូវសត្វរស់ ផលិត ផលមានដើមកំណើតពីសត្វ និងគ្រឿងបរិភោគគ្រប់ប្រភេទសំដៅថែរក្សាការពារ និង លើកកំពស់សុខភាព សាធារណៈ ។

www.pheakdeylaw.com

- លើកវិធានការទប់ស្កាត់តាមផ្លូវច្បាប់អោយមានប្រសិទ្ធភាពនូវការនាំចូលសត្វរស់ ផលិតផលមានដើមកំណើតពីសត្វ និងគ្រឿងបរិភោគគ្រប់ប្រភេទដែលខូចគុណភាព និងផ្ទុកទៅដោយមេរោគឆ្លង ដែលបណ្តាលអោយប៉ះពាល់ដល់សុខភាពសាធារណៈ និងអាយុជីវិតរបស់ប្រជាពលរដ្ឋ ។
- ចំពោះមុខត្រូវធ្វើការទប់ស្កាត់ជាបន្ទាន់នូវការនាំចូលសត្វជ្រូក និងគោដែលមានជម្ងឺឆ្កួតជាដើម ។
- ស្រាវជ្រាវរកអោយឃើញនូវបុគ្គលដែលបាននាំចូលសត្វរស់ ផលិតផលមានដើមកំណើតពីសត្វ និងគ្រឿងបរិភោគដែលខូចគុណភាព និងមានមេរោគឆ្លង និងមុខសញ្ញាដែលមានការពាក់ព័ន្ធ ដើម្បីបញ្ជូនទៅតុលាការវិនិច្ឆ័យទោសតាមច្បាប់ជាធរមាន ។
- ចាត់វិធានការរឹបអូស និងបំផ្លាញចោលមុខទំនិញខូចគុណភាព និងមានមេរោគឆ្លង ដែលបាននាំចូល ។
- ធ្វើរបាយការណ៍លំអិតជូនរាជរដ្ឋាភិបាល អំពីលទ្ធផលការងារដែលអនុវត្តបាន និងស្នើសុំយោបល់សំរេចពីរាជរដ្ឋាភិបាល ក្នុងករណីមានការចាំបាច់ ។

**ប្រការ ៣** : គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិរៀបចំលេខាធិការដ្ឋានមួយ ដើម្បីជំនួយការងារដែលមានទីតាំង និងសមាសភាពកំណត់ដោយឯកឧត្តមប្រធានគណៈកម្មការ និងមានសិទ្ធិប្រើប្រាស់របស់ក្រសួងសុខាភិបាល ។

**ប្រការ ៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួងស្ថាប័នពាក់ព័ន្ធ និងសមាភាពដូចមានចែង ក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ.ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

≈ ≈ ≈

www.pheakdeylaw.com